# ធម្មកថា

## របស់ព្រះតេជព្រះគុណបណ្ឌិត ហុក-សាវណ្ណ អំពីបូរាណសុភាសិតថា កង់ត្រាចកង់ធ្នង់ និងពុទ្ធភាសិតថា ច្រេះកើតពីដែក រមែងស៊ីនូវដែកវិញ

**Website: www.hoksavann.org**

ថ្ងៃទី១៦ តុលា ២០០៤

១- <u>បូរាណសុភាសិតថាកង់ត្រាចកង់ធ្នង់</u> ៖

ពាក្យថា«កង់ត្រាច់កង់ធ្នង់» គឺពោលដល់កង់រទេះដែលជនជាតិខ្មែរបានធ្វើកាលពីជំនាន់ដើម ។ គឺគេយកឈើត្រាចនិងឈើធ្នង់មកធ្វើជាកង់រទេះ ។ រង្វង់កង់នោះ គេយកឈើត្រាចពីរកង់ឈើធ្នង់ពីរកង់ មកដាក់ផ្គុំបញ្ចូលគ្នា ដោយធ្វើត្រាចធ្វើជាញី ឈើធ្នង់ធ្វើជាឈ្មោល ។ ពេលដែលកង់រទេះនោះវិលនៅលើដី ម្តងប៉ះឈើត្រាចម្តងប៉ះឈើធ្នង់ គឺកង់តែមួយ ប៉ុន្តែធ្វើពីឈើពីរមុខ កាលណាវិលទៅវាប៉ះដីម្តងម្នាក់ ។ ប៉ុន្តែសម័យក្រោយមក ពេលសម្បូណ៍ដែក រង្វង់កង់នោះ គេអាចយកឈើអ្វីមកធ្វើជាកង់ក៏បាន ព្រោះមានពាសដែកពីខាងក្រៅយ៉ាងមាំហើយ ។ ដូច្នេះ កង់ដែលវិលនៅលើដីនោះពុំប៉ះឈើទេ ប៉ះតែដែកដែលស្រោបពីក្រៅ ប៉ុន្តែវិលទៅវិលមកម្តងឈើត្រាចម្តងឈើធ្នង់ ។

ពាក្យថា«កង់ត្រាចកង់ធ្នង់»នេះ បើប្រៀបធៀបមកធម្មជាតិដទៃទៀត ដូចជាការផ្លាស់ប្តូររវាងថ្ងៃនិងយប់ ម្តងសុខម្តងទុក្ខ ម្តងចំរើនម្តងវិនាសជាដើម ។ ពាក្យនេះមានន័យដ៏សំខាន់ក្នុងបញ្ហាសង្គមមនុស្ស ។ តាមធម្មតា មនុស្សក្នុងលោកម្តងបានសុខម្តងបានទុក្ខ ម្តងមានម្តងក្រ ម្តងមានបុណ្យស័ក្តិម្តងអស់បុណ្យស័ក្តិ ។ ពាក្យនេះបានបង្រៀនមនុស្សឲ្យពិចារណា កុំឲ្យមើលងាយគ្នានៅពេលដែលមនុស្សកំពុងមានទុក្ខ ខ្សត់ខ្សោយទ្រព្យសម្បត្តិ គ្មានបុណ្យស័ក្តិ ចំណែកខ្លួនជាអ្នកមានភ័ព្វសំណាង កំពុងមានវត្ថុទាំងនេះ ព្រោះពេលណាមួយខ្លួនអាចធ្លាក់ខ្លួនដូចអ្នកនោះវិញក៏មាន ។ ព្រោះថាធម្មជាតិទាំងនេះ តែងស្ថិតនៅក្នុងសភាពមិនទៀង គឺពីសុខធ្លាក់មកជាទុក្ខ ពីមានមកក្រ ពីមានអំណាចមកអស់អំណាចវិញ ដូចកង់ត្រាចកង់ធ្នង់ វិលទៅវិលមកប៉ះដីម្តងម្នាក់ ដូច្នេះពុំត្រូវមើលងាយគ្នា ជិះជាន់គ្នាដោយមធ្យោបាយណាមួយឡើយ ។ មានពាក្យខ្មែរមួយបទពោលឡើងនៅពេលដែលទទួលទុក្ខទោសអ្វីមួយថា អូនអើយកុំសើចកុំយំបង ប្រយ័ត្នពៀរឆ្លងម្តងម្នាក់ ។ បើមានការជិះជាន់គ្នា ដូចជាអ្នកមានទៅជិះជាន់អ្នកក្រ អ្នកមានបុណ្យស័ក្តិទៅជិះជាន់អ្នកគ្មានបុណ្យស័ក្តិ អ្នកបានសុខទៅជិះជាន់អ្នកមានទុក្ខ ពេលប្រែត្រឡប់វិញ កើតទៅជាការសងសឹកគ្នាទៅវិញទៅមក ។

២- <u>ពុទ្ធភាសិតមួយបទពោលថា ច្រេះកើតអំពីដែករមែងស៊ីនូវដែកវិញ</u> ៖

ពុទ្ធភាសិតថា ច្រេះកើតអំពីដែករមែងស៊ីនូវដែកវិញ បើជាន័យអត្ថានុរូប គឺន័យសេចក្តីចំទៅតាមពាក្យមានសេចក្តីថា ដែកដែលគេដាក់ចោលនៅកណ្តាលវាលហាលថ្ងៃហាលខ្យល់ ឬទុកនៅកន្លែងពុំស្អាត ពុំបានថែទាំងវាទេ ដែកនោះតែងមានច្រេះចាប់ ។ ច្រេះជាធម្មជាតិមានពណ៌ខ្មៅ តែងស៊ីដែកបន្តិចម្តងៗ រហូតដែកនោះពុកផុយអស់តែម្តង ។ ច្រេះនេះកើតចេញមកអំពីដែក តែត្រូវស៊ីដែកខ្លួនឯងវិញ ។

ពុទ្ធភាសិតនេះ បើប្រៀបធៀបមកសង្គមមនុស្សវិញ ដែកប្រៀបដូចបុគ្គលណាម្នាក់ដែលធ្វើអាក្រក់ ច្រេះប្រៀបមកអំពើអាក្រក់របស់បុគ្គលនោះ ស៊ីដែកគឺផលរបស់អំពើអាក្រក់តាមឲ្យផលបុគ្គលនោះ ។ បានសេចក្តីថា បុគ្គលប្រាថ្នាសេចក្តីសុខឲ្យដល់ខ្លួន បែរទៅជាបៀតបៀនអ្នកដទៃ បុគ្គលនោះពុំបានសេចក្តីសុខឡើយ ព្រោះប្រព្រឹត្តអំពើបាបកម្មនៅឲ្យមានទុក្ខ ដែលផ្ទុយអំពីមាគ៌ាដែលនាំឲ្យបានសុខ ហើយផលនៃអំពើបាបនោះតែងសម្លាប់បុគ្គលនោះវិញ ។ មួយទៀត បុគ្គលដែលសាងអំពើអាក្រក់ ពុំឈ្មោះថាស្រឡាញ់ខ្លួនឡើយ ឈ្មោះថាជាអ្នកស្អប់ខ្លួនឯង ព្រោះផលនៃអំពើបាបនោះ តែងផ្តល់នូវសេចក្តីទុក្ខឲ្យដល់ខ្លួន ។ ប្រៀបដូចជនផ្តាច់ការនៃប្រទេសណាមួយ ដែលអនុវត្តផែនការមិនឲ្យមានអ្នកជំទាស់ ដោយបំបិទសិទ្ធិគ្រប់បែបយ៉ាងរបស់ប្រជាពលរដ្ឋ រហូតប្រើអំពើហឹង្សាក្នុងទីចំពោះមុខនិងកំបាំងមុខ គឺលួចសម្លាប់ដើម្បីពង្រឹងអំណាច ជនផ្តាច់ការនោះ ទីបំផុតនឹងគេចមិនផុតពីទោសទណ្ឌកម្ម ដែលខ្លួនបានប្រព្រឹត្តឡើយ ។ ក៏ដូចគ្នានឹងប្រទេសណាមួយ បានឈ្លានពានប្រទេសមួយទៀត ដែលគេចមិនផុតពីទោសទណ្ឌកម្មពីច្បាប់អន្តរជាតិឡើយ ។ ដូចពុទ្ធភាសិតដែលបានពោលមកហើយថា ច្រេះកើតអំពីដែករមែងស៊ីនូវដែកវិញដូច្នេះដែរ ។៚

❑